វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

*The NGO Forum on Cambodia*

ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង

*Working Together for Positive Change*

# កំណត់ហេតុ

# កិច្ចប្រជុំសមាជិកប្រចាំត្រីមាស




ថ្ងៃសុក្រ ទី១១ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោង ០៨ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់

ទីកន្លែង: មជ្ឈមណ្ឌលព័ន្ធកិច្ចឯកភាពគ្រីស្ទបរិស័ទភ្នំពេញ ***(PPEDC)***

# កំណត់ហេតុ
# កិច្ចប្រជុំសមាជិកប្រចាំត្រីមាស
## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

ថ្ងៃសុក្រ ទី១១ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោង ០៨ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់

ទីកន្លែងៈ មជ្ឈមណ្ឌលព័ន្ធកិច្ចឯកភាពគ្រីស្ទបរិស័ទភ្នំពេញ ***(PPEDC)***

**៙✵៙**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានរៀបចំកិច្ចប្រជុំសមាជិកប្រចាំត្រីមាសជាលើកទីបីរបស់ខ្លួន កាលពីថ្ងៃសុក្រ ទី១១ ខែតុលា ឆ្នាំ២០១៣ នៅសាលប្រជុំនៃ មជ្ឈមណ្ឌលព័ន្ធកិច្ចឯកភាពគ្រីស្ទបរិស័ទភ្នំពេញ (PPEDC)។ កិច្ចប្រជុំបានចាប់ផ្តើមនៅម៉ោង ០៨ ព្រឹក និងបញ្ចប់នៅម៉ោង ១២ ថ្ងៃត្រង់ ដែលមានអ្នកចូលរួមសរុបចំនួន ១២៩ នាក់ (ក្នុងនោះមានស្ត្រី ៤៩ នាក់) មកពីខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ដែលជាតំណាងមកពីអង្គការសមាជិក តំណាងអង្គការសង្គមស៊ីវិល និងសមាជិកបណ្តាញ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។

## ១. មតិស្វាគមន៍របស់ប្រធានអង្គប្រជុំ




**លោក គាម មករាឌី** នាយកកម្មវិធីបរិស្ថាន និងសុខភាព នៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍ កសិកម្មកម្ពុជា (CEDAC) និងជាសមាជិកគណៈកម្មការគ្រប់គ្រងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានជំរាបពីគោលបំណង ដូចជា ១) រាយការណ៍អំពីលទ្ធផលសម្រេចបានកន្លងមក ២) លើកយកបញ្ហាអាទិភាព ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយ ៣) ទទួលយកមតិយោបល់ និងសំណូមពរសម្រាប់កែលំអ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ សមាជិក សរុប ៩០ អង្គការ ជាង ៦០ ភាគរយ ជាអង្គការក្នុងស្រុក និងសមាជិកបណ្តាញជាង ២៥០ អង្គការ ក្នុងបណ្តាញដែលសម្របសម្រួលដោយ NGO Forum ដែលក្នុងនោះមាន បណ្តាញសម្ព័ន្ធទន្លេកម្ពុជា បណ្តាញកសិកម្ម និង សន្តិសុខស្បៀង បណ្តាញព្រៃឈើ បណ្តាញប្រែប្រួលអាកាសធាតុ បណ្តាញបញ្ហាអភិវឌ្ឍន៍ និង បណ្តាញវេដបូក។ យើងបានទទួលលទ្ធផលសំខាន់ៗមួយចំនួន ដូចជា រដ្ឋាភិបាលបានផ្អាកសម្បទានសេដ្ឋកិច្ច រដ្ឋាភិបាលទទួលយកធាតុចូលមួយចំនួនរបស់សង្គមស៊ីវិល ការរៀបចំបង្កើតច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងយោបល់មួយចំនួនត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម រដ្ឋាភិបាលទទួលស្គាល់លើ

ប្រសិទ្ធភាពការងារ លើតម្លាភាព និងភាពជាគម្រូ ការផ្តល់មតិយោបល់លើ REDD+ តាមរយៈវេទិកា និងកិច្ចប្រជុំផ្សេងៗ។ លោកក៏បានថ្លែងអំណរគុណចំពោះសមាជិក សមាជិកា ទាំងអស់ បន្តខិតខំប្រឹងប្រែងបន្តទៀត តាមរយៈការចូលរួមផ្តល់នូវមតិយោបល់។

## ២. កិច្ចពិភាក្សាលើក្របខណ្ឌមូលនិធិប្រែប្រួលអាកាសធាតុ

### ២.១ ស្ថានភាពនៃការរៀបចំក្របខណ្ឌមូលនិធិប្រែប្រួលអាកាសធាតុនៅកម្ពុជា




**លោក ម៉ា ច័ន្ទសុទ្ធា** អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន បាន បង្ហាញអំពីហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ បទពិសោធន៍របស់ប្រទេសកម្ពុជា ដោយបានលើកឡើង ពីប្រភពហិរញ្ញវត្ថុដែលមានថវិកាសរុបច្រើនជាង ២០០ លានដុល្លារ សម្រាប់កម្មវិធីប្រែប្រួលអាកាស ធាតុ ក្នុងរយៈពេល ៣ ទៅ ៤ឆ្នាំ ដែលភាគច្រើនគាំទ្រលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ តាម រយៈការសិក្សាថ្មីៗ ជាង ៨៦ ភាគរយ ជំនួយលើបញ្ហាប្រែប្រួលអាកាសធាតុ មានប្រភពពីខាងក្រៅ ក្នុង នោះមាន CIF (PPCR/SPCR), GEF, Adaptation Fund, UNDP, USAID, SIDA, Japan និង EU។ មូលនិធិទ្រទ្រង់វិស័យអាទិភាពរបស់ជាតិ រួមមាន សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ (CCCA) សហភាពអឺរ៉ុប (EU) ភ្នាក់ងារអភិវឌ្ឍន៍ស៊ុយអែដ (SIDA) ដាណឺម៉ាក (DANIDA) និងកម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ (UNDP)។ ស្ថាប័នរដ្ឋាភិបាលភាគច្រើនបានទទួលការគាំទ្រពី CIF, GEF មូលនិធិ បន្សាំ កម្មវិធីសហប្រជាជាតិ និងជំនួយប្រទេសជប៉ុន។ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ក៏បានការ គាំទ្រជំនួយពី USAID កម្មវិធីបន្សាំដោយសហគមន៍ស៊ុយអែដ (SIDA) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ហើយការគាំទ្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសម្ព័ន្ធភាពប្រែប្រួលអាកាស ធាតុ (CCCA)។ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ ដែលមានគណៈកម្មការជាតិប្រែប្រួលអាកាសធាតុកម្ពុជា បានចាត់ចែងពហុជំនួយសរុប ១១ លានដុល្លារ សម្រាប់គម្រោងចំនួន ២០ ក្នុងនោះ រដ្ឋាភិបាល ទទួលបាន ១៤ គម្រោង និងអង្គការមិនមែនរដ្ឋាភិបាល ទទួលបាន ០៦ គម្រោង ដើម្បីឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងបង្កើនសមត្ថភាពដៃគូ រវាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋា ភិបាល និងគ្រឹះស្ថានសិក្សា។ គម្រោងទាំងនោះផ្តោតជាសំខាន់លើ សត្វពាហនៈ ជំងឺបង្កដោយទឹក ការបន្សាំផ្អែកលើស្ថានប្រព័ន្ធ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ទឹកស្អាត និងអនាម័យ និងការ ឆ្លើយតបនឹងការប្រែប្រួលអាកាធាតុនៅថ្នាក់ក្រោមជាតិ។ មូលនិធិត្រូវបានផ្តល់ដល់គម្រោងសាកល្បង ក្នុងស្រុកចំនួន ០៣ តាមរយៈសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ (២០១១-២០១៣) ដើម្បីពង្រឹងសមត្ថ ភាព និង

ដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុក្នុងផែនការថ្នាក់ក្រោមជាតិ។ ជំហានបន្ទាប់ ត្រូវរៀបចំ CCCSP ផែនការថ្នាក់ក្រសួង និង CCFF ការកែសម្រួលបែបបទឲ្យស្របនឹងផែនការយុទ្ធសាស្ត្រ សម្រួលយន្តការរៀបចំផែនការ និងថវិកា សម្រួលយន្តការតាមដាន និងវាយតម្លៃ ការគ្រប់គ្រងចំណេះ ដឹង។ គណៈកម្មការជាតិប្រែប្រួលអាកាសធាតុ មានតួនាទីប្រឹក្សា និងរៀបចំហិរញ្ញប្បទាន និងយុទ្ធ សាស្ត្រ និងធ្វើជាអង្គភាពអនុវត្តន៍ជាតិ។

## ២.២ របកគំហើញពីការប្រើប្រាស់ថវិកាប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា




**លោក ហេង ភក្តី** អ្នកសិក្សាស្រាវជ្រាវឯករាជ្យ បានបង្ហាញនូវសារតានៃការសិក្សាស្រាវជ្រាវ ដែលហិរញ្ញប្បទានអាកាសធាតុ ត្រូវបានផ្តល់តាមរយៈស្ថាប័នជាតិ តំបន់ និងអន្តរជាតិ សម្រាប់គម្រោងកម្មវិធីការកាត់បន្ថយ និងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។ ហិរញ្ញប្បទានអាកាសធាតុចាំបាច់ សម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ ដូចដែលពិធីសារក្យូតូបានចែងថា ប្រទេសរីកចំរើន ត្រូវ ផ្តល់ហិរញ្ញប្បទានដើម្បីជួយដល់ប្រទេសក្រីក្រ។ ប្រទេសកម្ពុជាជាប្រទេសមួយ ក្នុងចំណោមបណ្តា ប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ និងត្រូវការធនធានហិរញ្ញវត្ថុយូរអង្វែង ដើម្បីដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ហើយព័ត៌មានពីហិរញ្ញប្បទានប្រែប្រួលអាកាសធាតុមានតិចតួច។ មូលហេតុដែលនាំឲ្យមានការសិក្សាស្រាវជ្រាវនេះ គឺ ប្រទេសកម្ពុជាប្រឈមនឹងគោលនយោបាយ និងប្រព័ន្ធ ក្នុងការទទួល និងផ្តល់ហិរញ្ញប្បទានអាកាស ធាតុ បង្កើន និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាព និងស្វែងយល់ពីភាពជោគជ័យ និងបញ្ហា ប្រឈមក្នុងការគ្រប់គ្រងមូលនិធិប្រកបដោយប្រសិទ្ធិភាព។ ការសិក្សាស្រាវជ្រាវនេះ មានគោលបំណង ដើម្បីកំណត់ និងចងក្រងឯកសារស្តីពីមូលនិធិទ្វេរភាគី និងពហុភាគី ដែលប្រទេសកម្ពុជាទទួលបាន វិភាគដំណើរការ និងបញ្ហាប្រឈមនឹងហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនានា នៅកម្រិតគោលនយោ បាយ និងការអនុវត្ត ព្រមទាំងផ្តល់អនុសាសន៍លើជំហាន ក្នុងការបង្កើនលទ្ធភាពគ្រប់គ្រងការប្រើប្រាស់មូលនិធិប្រែប្រួលអាកាសធាតុឲ្យបានប្រសើរ និងមានប្រសិទ្ធិភាព។ វិធីសាស្ត្រដែលបានប្រើសម្រាប់ការសិក្សាស្រាវជ្រាវនេះ គឺ ការប្រមូលទិន្នន័យបែបបរិមាណ និងគុណភាព ទិន្នន័យសម្ភាសន៍អ្នកពាក់ព័ន្ធ (៥៩ នាក់) និងករណីសិក្សា (០២ ករណីសិក្សា) និងសិក្ខាសាលា ០២លើក។ ប្រភពទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ បានមកពីទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គម្រោងប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ទិន្នន័យមូលនិធិពហុភាគី ពិគ្រោះយោបល់ផ្ទាល់ជាមួយម្ចាស់ជំនួយ និងភ្នាក់ងារអភិវឌ្ឍន៍ ហើយមានគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុចំនួន ៩៥។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា

ចាប់ពីឆ្នាំ២០០៣ ប្រទេសកម្ពុជាបានទទួលហិរញ្ញប្បទានសរុប ៦៥៥,៦លានដុល្លារ នៃមូលនិធិប្រែប្រួលអាកាសធាតុ ក្នុងនោះ ៦៤ ភាគរយ ជាជំនួយឥតសំណង និង ៣៦ ភាគរយ ជាកម្ចី។ ក្នុងចំណោមមូលនិធិសរុប ៦៥៥,៦ លានដុល្លារ ត្រូវបានគៀងគរសម្រាប់កម្ពុជាប្រមាណ ៣៣៨,៨ លានដុល្លារ បានប៉ាន់ប្រមាណថា នឹងត្រូវចំណាយ ហើយ ៣១៦,៨ លានដុល្លារ នៅមានសម្រាប់ ២០១៤-២០២០។ ប្រភពហិរញ្ញប្បទានទ្វេរភាគមាន ៤៨ ភាគរយ និងពហុភាគី ៥២ ភាគរយ។ ការផ្តល់ហិរញ្ញប្បទានដល់ប្រទេសកម្ពុជាសម្រាប់ការប្រែប្រួលអាកាសធាតុ រួមមាន ជំនួយឥតសំណង និងកម្ចី ពីម្ចាស់ជំនួយច្រើនជាងគេ មាន ធនាគារអភិវឌ្ឍន៍អាស៊ី (ជំនួយ ២៥ លានដុល្លារ និងកម្ចី ១២០,៩៣ លានដុល្លារ) CIF (ជំនួយ ៥៥,៣ លានដុល្លារ និង កម្ចី ៣៦ លានដុល្លារ) ប្រទេសជប៉ុន (ជំនួយ ៥១,១៤ លានដុល្លារ និង កម្ចី ១១,២៦ លានដុល្លារ) ប្រទេសបាំរាំង (ជំនួយ ២១,៥២លានដុល្លារ និង កម្ចី ១៨,៣៧ លានដុល្លារ) សហរដ្ឋអាមេរិក (ជំនួយ ៣៨ លានដុល្លារ) ធនាគារពិភពលោក (ជំនួយ ១៣,៥ លានដុល្លារ និង កម្ចី ១០ លានដុល្លារ) មូលនិធិបរិស្ថានពិភពលោក (ជំនួយ ២៥,៥ លានដុល្លារ) IFAD (ជំនួយ ១៨,៦ លានដុល្លារ និង កម្ចី ១,៩ លានដុល្លារ) និងបណ្តាម្ចាស់ជំនួយផ្សេងទៀត ដូចជា ប្រទេសចិន (កម្ចី) ប្រទេសអាល្លឺម៉ង់ (ជំនួយ) ដាណឺម៉ាក (ជំនួយ) សហគមន៍អឺរ៉ុប (ជំនួយ) អូស្ត្រាលី (ជំនួយ) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មូលនិធិបន្ស៊ាំ UN-REDD ជាដើម។ ហិរញ្ញប្បទានត្រូវបានផ្តល់លើវិស័យកសិកម្ម ធនធានទឹក (៤១ ភាគរយ) ថាមពល (១៤ ភាគរយ) គ្រប់គ្រងគ្រោះមហន្តរាយ (១៦ ភាគរយ) និងវិស័យផ្សេងៗទៀត ដូចជា ពង្រឹងសមត្ថភាពហិរញ្ញវត្ថុ ព្រៃឈើ ធនធានធម្មជាតិ គោនយោបាយ ពហុវិស័យ ដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ។ ហិរញ្ញប្បទានដែលបានផ្តល់ផ្តោតលើសកម្មភាពបន្ស៊ាំ (៧០ ភាគរយ) សកម្មភាពកាត់បន្ថយ (២២ ភាគរយ) គោលនយោបាយស្រាវជ្រាវ ពង្រឹងសមត្ថភាព (០៤ ភាគរយ) និងកាត់បន្ថយនិងបន្ស៊ាំ (៤ភាគរយ)។ បណ្តាខេត្តដែលបានទទួលហិរញ្ញប្បទានភាគច្រើនមាន ពោធិសាត់ បាត់ដំបង កំពង់ឆ្នាំង និង សៀមរាប ព្រមទាំងខេត្តព្រៃវែង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពត ស្វាយរៀង ក្រចេះ ទទួលបានហិរញ្ញប្បទានមធ្យម។ មកដល់ពេលនេះ ប្រទេសកម្ពុជាសម្រេចជោគជ័យក្នុងការគៀងគរមូលនិធិផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុជាតិ បញ្ចប់នូវការពិនិត្យឡើងវិញនូវចំណាយ សាធារណៈ និងស្ថាប័នលើការប្រែប្រួលអាកាសធាតុ ផែនការសកម្មភាពថ្នាក់ក្រសួង ក្របខណ្ឌហិរញ្ញ ប្បទានប្រែប្រួលអាកាសធាតុ និងការសន្យាប្រើប្រាស់មូលនិធិប្រកបដោយប្រសិទ្ធិភាព។ ការសិក្សា ស្រាវជ្រាវបានរកឃើញបញ្ហាប្រឈមមួយចំនួន មានខ្វះក្របខណ្ឌតាមដាន និងរាយការណ៍ ខ្វះទិន្នន័យ តាមដានថវិកា ខ្វះភាពជាម្ចាស់ចំពោះការចូលរួម ការអនុវត្ត តាមដាន និង វាយតម្លៃ ខ្វះការចូលរួមពីអ្នក ពាក់ព័ន្ធ ជាពិសេស សហគមន៍រងផលប៉ះពាល់ ការយល់ដឹងរបស់ប្រជាជននៅកម្រិតទាប សមត្ថភាព របស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅមានកម្រិត ការសម្របសម្រួលរវាងក្រសួង និងម្ចាស់ ជំនួយ ការអនុវត្តរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅមានកម្រិត។ មានចំនុចមួយចំនួន សម្រាប់រដ្ឋាភិបាលពិចារណា

ដូចជា ការភ្ជាប់ហិរញ្ញប្បទានអាកាសធាតុជាមួយនឹងផែនការអភិវឌ្ឍន៍ កម្ពុជា សុខដុមរមនីយកម្មរបាយការណ៍ ប្រព័ន្ធកត់ត្រា និងតាមដានលំហូរហិរញ្ញប្បទានប្រែប្រួល អាកាសធាតុ ធ្វើឲ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាពចំពោះគ្រប់ភាគីពាក់ព័ន្ធ ពង្រឹង និងលើកកម្ពស់ការផ្តល់ហិរញ្ញប្បទានតាមរយៈថ្នាក់ក្រោមជាតិ និង កែលំអការសម្របសម្រួលថ្នាក់អន្តរក្រសួង។ សម្រាប់ម្ចាស់ជំនួយ ចំនុចមួយចំនួនដូចជា លើកកម្ពស់ភាពជាម្ចាស់របស់ប្រទេស លើកកម្ពស់យន្តការផ្តល់ហិរញ្ញប្បទាន បន្តបង្កើនការយល់ដឹង និងពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាល និងសង្គមស៊ីវិល និង ធ្វើឲ្យការខិតខំប្រឹងប្រែងប្រសើរឡើង ដើម្បីធ្វើសុខដុមរមនីយកម្មប្រព័ន្ធ។ សម្រាប់អង្គការអនុវត្ត មានចំណុចគួរពិចារណាមួយចំនួន ដូចជា ចងក្រងមេរៀនបទពិសោធន៍ និងចែករំលែកបទពិសោធន៍នៃការអនុវត្តគម្រោងប្រែប្រួលអាកាសធាតុ ផ្តល់ឲ្យសហគមន៍មូលដ្ឋានចូលរួមក្នុងដំណើរការរៀបចំផែនការគម្រោងរហូតដល់វាយតម្លៃបញ្ចប់គម្រោង យកចិត្តទុកដាក់ចំពោះអ្នកទទួលផល និងធ្វើការយ៉ាងជិតស្និទ្ធនឹងរដ្ឋាភិបាលដើម្បីចែករំលែកព័ត៌មាន។ ការសិក្សានេះក៏បានភ្ជាប់ជាមួយនូវបញ្ជីអ្នកពាក់ព័ន្ធ និងឯកសារយោង។

## កិច្ចពិភាក្សា

**<u>សំនួរៈ</u>**

- **លោក មាស ចាន់ធីៈ** ប្រទេសកម្ពុជា និងហ្វីលីពីន ងាយរងគ្រោះ តើមានកត្តាអ្វីខ្លះនាំឲ្យមានភាពងាយរងគ្រោះ?
- **លោក ជីវ យូម៉េង** មកពី DCA/CA: តើមានភាពជោគជ័យអ្វីខ្លះ? តើមានការចែករំលែកដល់ មូលដ្ឋានដែរ ឬទេ? តើមានលក្ខណៈវិនិច្ឆ័យក្នុងការផ្តល់ហិរញ្ញប្បទានអ្វីខ្លះ?
- **លោក មករា**: តើក្រសួងបរិស្ថានមានយន្តការអ្វីខ្លះក្នុងការបញ្ចៀសហានិភ័យ ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ? តើក្រសួងបរិស្ថានមានយុទ្ធសាស្ត្រអ្វី ដើម្បីដោះស្រាយចំពោះគ្រោះធម្មជាតិបច្ចុប្បន្ន?

**<u>ចម្លើយៈ</u>**

- **លោក ហេង ភក្តីៈ** កត្តាដែលបានកំណត់ថា ប្រទេសកម្ពុជា និងហ្វីលីពីន ជាប្រទេសងាយរងគ្រោះ មានគ្រោះធម្មជាតិដោយសារទឹកជំនន់ និងរាំងស្ងួត និង កត្តាសមត្ថភាពក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងហេដ្ឋារចនាសម្ព័ន្ធមានកម្រិត។

- **លោក ម៉ា ច័ន្ទសុទ្ធាៈ** គម្រោងសាកល្បងមាន ០៣ គម្រោង បន្ទាប់ពីពិនិត្យឃើញថា គម្រោងណាមួយដែលមានភាពលេចធ្លោជាងគេ នឹងទទួលបានហិរញ្ញប្បទានបន្ថែម ដោយមានក្រុមការងារមួយត្រួតពិនិត្យ និង វាយតម្លៃ។ គណៈកម្មការវាយតម្លៃ ដែលមានជំហាននៃការវាយតម្លៃផ្សេងគ្នា ដំណាក់កាលទី១ រដ្ឋបាល ទាក់ទងនឹងការរៀបចំឯកសារ ឬសំណើ ទី២ ទាក់ទងនឹងការវាយតម្លៃលើយុទ្ធសាស្ត្រក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ចំពោះសំណើដែលមានការអនុវត្តដោយសង្គមស៊ីវិលតែឯកឯង នឹងមានលទ្ធភាពទទួលបានជាង ១០ ម៉ឺនដុល្លារ ករណីដែលគម្រោងមានកិច្ចសហការរវាងសង្គមស៊ីវិល និងស្ថាប័នរដ្ឋាភិបាល មានលទ្ធភាពទទួលបានរហូតដល់ ២០ ម៉ឺនដុល្លារ។ ក្រសួងបរិស្ថានមានច្បាប់មួយចំនួនទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងផែនការសកម្មភាពលម្អិត ស្ថិតនៅក្រោមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការអនុវត្តដល់មូលដ្ឋានជាក់ស្តែង។

## ៣. ការណែនាំអំពីការបោះឆ្នោតគណៈកម្មការគ្រប់គ្រង

**លោក តឹក វណ្ណារ៉ា** នាយប្រតិបត្តិរង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានធ្វើការណែនាំដល់តំណាងអង្គការដែលឈរឈ្មោះបោះឆ្នោត មាន ០៤ រូប ដូចមានរាយនាមខាងក្រោម៖

| ឈ្មោះបេក្ខជន | ស្ថាប័ន | សម្លេង |
|---|---|---|
| លោក រិទ្ធិ ប៊ុនរឿន | AFD | 7 |
| លោក ឱម សារ៉ាត | FACT | 7 |
| លោក វ៉ា មឿន | Mlup Baitong | 12 |
| លោក មុត សាណា | Save the Children | 16 |
| | សរុប | **42** |

## ការថ្លែងអំណរគុណចំពោះសមាជិកគណៈកម្មការគ្រប់គ្រង




**លោក ឈិត សំអាត** បានជម្រាបថា សមាជិកគណៈកម្មាធិការគ្រប់គ្រងរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា មាន ០៧ រូប រួមមាន លោក គាម មករាឌី ២) លោក ឡាត់ គី ៣) លោកស្រី ថៃ បូណេ ៤) លោក ងិន សៅរ័ត្ន ៥) លោកស្រី ព្រី ផល្លីភួង ៦) លោកស្រី តែ សុខវី (ជំនួសលោក ស៊ុន យូរ៉ា ដែលបានលាលែង

ពីតំណែងមុនចប់អណត្តិ) និង ៧) លោក មុត សាណា (ជំនួស លោក សុន សុងហាក់ ដែលបានលាលែងពីតំណែងមុនចប់អណត្តិ)។ គណៈកម្មាធិការទាំងអស់មានតួនាទីគ្រប់គ្រង និងវាយតម្លៃ នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និង អនុម័តលើផែនការ និងថវិការបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ លោកក៏បានថ្លែងអំណរគុណចំពោះសមាជិកគណៈកម្មាធិការចាស់ និងស្វាគមន៍សមាជិកគណៈកម្មាធិការថ្មី ដែលបាន ទទួលការគាំទ្រតាមរយៈការបោះឆ្នោត។

តំណាងរបស់អង្គការសង្គ្រោះកុមារ (Save the Children) ជំនួសឲ្យ លោក មុត សាណា បានប្តេជ្ញាក្នុងការរួមចំណែកជួយដល់ជនដែលងាយរងគ្រោះ និងការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។

**លោក ឈិត សំអាត** បានលើកឡើងថា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ធ្វើការងារផ្តោតលើបញ្ហារសើបទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ ដោយអនុវត្តការងារដោយតម្លាភាព និងគណនេយ្យភាព។ ក្នុងពេលថ្មីៗនេះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានទទួលវិញ្ញាបនប័ត្រលើអភិបាលកិច្ចល្អជាលើកទីពីរ។

## ៤. អនុសាសន៍សំខាន់ៗ របស់អង្គការសង្គមស៊ីវិលសម្រាប់ជាធាតុចូលក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨

**លោក ផែន រស្មី** អ្នកសម្របសម្រួលគម្រោងគោលនយោបាយអភិវឌ្ឍន៍ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានបង្ហាញលទ្ធផលនៃការពិគ្រោះយោបល់របស់អង្គការសង្គមស៊ីវិល ដោយបានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨។ ចាប់ពីដើមឆ្នាំ២០១៣ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានប្រមូលយោបល់ និងធាតុចូលពីអង្គការសង្គមស៊ីវិលលើ ១១ វិស័យ រួមមាន បរិយាកាសអំណោយផល មីក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសេដ្ឋកិច្ច ចំណេះដឹងខាងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ភាពក្រីក្រ និងអសមធម៌ អប់រំ សុខភាព ទឹកស្អាត និងអនាម័យ ការអភិវឌ្ឍន៍វប្បធម៌សង្គម បរិស្ថាន បញ្ហាគ្រប់វិស័យ ដោះមីន និងការតាមដាន និងវាយតម្លៃ។ ផ្នែកសំខាន់ៗ ០២ គឺៈ ការអនុវត្ត និងការពង្រឹងការអនុវត្ត ព្រមទាំងការអភិវឌ្ឍន៍បែតង ត្រូវបានស្នើដាក់បញ្ចូលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មនេះ។ សារៈសំខាន់នៃការចូលរួម របស់អង្គការសង្គមស៊ីវិល ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ ដោយសារភាពជាម្ចាស់លើគោលនយោបាយជាតិ សង្គមស៊ីវិលមានបទពិសោធន៍ក្នុងការកាត់បន្ថយភាពក្រីក្រជាមួយអ្នកក្រីក្រ តួនាទីរបស់សង្គមស៊ីវិលក្នុងការកំណត់អាទិភាព បង្កើតគោលនយោបាយ បែងចែកធនធានសម្រាប់ការអនុវត្តកម្មវិធី តាមរយៈកិច្ចពិគ្រោះយោបល់លើផែនការជាតិ។ សង្គមស៊ីវិលអាចចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ ដោយចែករំលែកការងារដល់ថ្នាក់មូលដ្ឋានចំពោះការបង្កើតគោលនយោបាយ រួមចំណែកកែលំអធាតុ

ចូល ដែលរៀបចំដោយក្រសួងពាក់ព័ន្ធ ជួយរដ្ឋាភិបាលរៀបចំប្រព័ន្ធឆ្លើយតបនឹងតម្រូវការពលរដ្ឋកម្ពុជា និងជួយផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨។ កម្មវិធីបញ្ហាអភិ-វឌ្ឍន៍បានសម្របសម្រួលអង្គការសង្គមស៊ីវិល ក្នុងការរៀបចំធាតុចូលសម្រាប់ផែនការយុទ្ធសាស្ត្រអភិ- វឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ កាលពីខែមករា និងខែមេសា ឆ្នាំ២០១៣។ ឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ លើកឡើងពីដំណើរការ បញ្ហាប្រឈម ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។ ទស្សនៈសំខាន់ៗស្នើឡើងសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ និងឱកាសសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិល។ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ អង្គការសង្គមស៊ីវិលធ្វើការងារដោយផ្ទាល់ជាមួយក្រសួងពាក់ព័ន្ធ តាមរយៈការចងក្រងនិងពិនិត្យលើយោបល់និងធាតុចូល ដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ការដាក់ឥទ្ធិពលលើគណបក្សនយោបាយ កាលពីខែឧសភា និងខែមិថុនា និងបញ្ចុះបញ្ចូលដៃគូអភិវឌ្ឍន៍នានា។ ជាលទ្ធផល អង្គការសង្គមស៊ីវិលតាមវិស័យ ចំនួន ២២ ដែលបានបញ្ជ្រាបបញ្ហាយេនឌ័រផងដែរ បានធ្វើជូននូវយោបល់ជូនវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ សម្រាប់ពិនិត្យ និងចងក្រង។ ទស្សនៈយោបល់ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិល សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ បានផ្តោតលើអភិបាលកិច្ចល្អ ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ ការអភិវឌ្ឍន៍មនុស្ស និងសង្គម និងបរិយាកាសសម្រាប់ការអភិវឌ្ឍន៍។

**អភិបាលកិច្ចល្អ** ផ្តោតសំខាន់លើសេចក្តីព្រាងច្បាប់សិទ្ធិទទួលបានព័ត៌មាន ការផ្សព្វផ្សាយឯកសារថវិកា តម្លាភាពជំនួយទាក់ទងនឹងព័ត៌មាន និងលក្ខខណ្ឌផ្តល់កម្ចីរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បង្កើនកិច្ចពិគ្រោះយោបល់សាធារណៈចំពោះសេចក្តីព្រាងច្បាប់នានា និងច្បាប់និស្សារណកម្ម ធានាឯករាជ្យភាពរបស់តុលាការ និងអនុលោមភាពមូលដ្ឋានគ្រឹះនៃសេចក្តីព្រាងច្បាប់។

**ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ** ផ្តោតលើការកំណត់ព្រំប្រទល់ដីរបស់រដ្ឋ ប្រកបដោយ តម្លាភាព និងច្បាស់លាស់ ធានានូវការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ធានានូវការពិគ្រោះយោបល់ និងការសម្រេចចិត្ត ដោយមានការចូលរួមពីពលរដ្ឋទាំងអស់ រស់នៅក្នុងតំបន់គម្រោង និងរៀបចំវេទិកាសាធារណៈ ០២សប្តាហ៍បន្ទាប់ពីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបានបញ្ចប់ អនុម័តលើការអនុវត្តប្រសើរបំផុតមានលក្ខណៈអន្តរជាតិចំពោះការផ្តល់សំណងដល់សហគមន៍រងផលប៉ះពាល់ដោយគម្រោងទំនប់វារីអគ្គិសនី បង្កើតច្បាប់ និងគោលនយោបាយបន្ថែម ទាក់ទងនឹងបញ្ហាដីធ្លី និងផ្ទះសម្បែង ពង្រឹងសមត្ថភាពលើការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ ពង្រឹងសេណារីយ៉ូ និងគ្រោងការណ៍ដើម្បីធានាយន្តការតាមដាន។

**ការអភិវឌ្ឍមនុស្ស និងសង្គម** ផ្តោតលើការកែលំអគុណភាពសេវាអប់រំ ពង្រឹងការអនុវត្ត និងតាមដានវាយតម្លៃយុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ ដាក់បញ្ចូលបញ្ហាយេនឌ័រក្នុងគ្រប់វិស័យនៃផែនការអភិវឌ្ឍន៍ជាតិ និងបង្កើនថវិកាសមស្របសម្រាប់កែលំអការប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យ។

**បង្កបរិយាកាសអភិវឌ្ឍន៍** ផ្តោតលើក្របខណ្ឌអភិវឌ្ឍន៍ដែលលើកទឹកចិត្តការចូលរួមរបស់សង្គមស៊ីវិល និងពលរដ្ឋក្នុងដំណើរការធ្វើផែនការ អនុវត្ត តាមដាន និងវាយតម្លៃ ដោយផ្អែកលើសុចនាករតាមដានរួម ឆ្លើយតបជាវិជ្ជមានដល់ប្រជាជនទាក់ទងនឹងផលប៉ះពាល់ពីការអភិវឌ្ឍ យន្តការទូលំទូលាយសម្រាប់កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ នៅថ្នាក់ក្រោមជាតិជាមួយពលរដ្ឋ បង្កើនការយល់ដឹងពីកម្មវិធីអភិវឌ្ឍន៍ គោនយោបាយ និងច្បាប់ ហើយធានានូវតម្លាភាពគោលនយោបាយ និងដំណើរការអនុវត្តផែនការ។ ទិសដៅខាងមុខ អង្គការសង្គមស៊ីវិលនឹងរៀបចំកិច្ចពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ បន្តតាមដានសេចក្តីព្រាងលើកទី១នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ ក្នុងខែធ្នូ ឆ្នាំ២០១៣ និងប្រើប្រាស់ឯកសារគោលជំហរដើម្បីតាមដានដំណើរការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។

## ៥. លទ្ធផលសំខាន់ៗ នៃសន្និសិទសង្គមស៊ីវិលអាស៊ីប៉ាស៊ីហ្វិចស្តីពីនិរន្តរភាពបរិស្ថាន




**លោក តឹក វណ្ណារ៉ា** នាយកប្រតិបត្តិរង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានបង្ហាញពីលទ្ធផលនៃសន្និសីទសង្គមស៊ីវិលអាស៊ីប៉ាស៊ីហ្វិចស្តីពីនិរន្តរភាពបរិស្ថាន ក្នុងរបៀបវារៈនៃការអភិវឌ្ឍក្រោយឆ្នាំ ២០១៥ និងគោលដៅនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលកិច្ចប្រជុំនេះមានគោលបំណងដើម្បីធានានិរន្តរភាពបរិស្ថាន ក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព យន្តការសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងសង្គមស៊ីវិល និងតម្លាភាពដែលសង្កត់ធ្ងន់ទៅលើការចូលរួមរបស់សង្គមស៊ីវិល ក្នុងការកំណត់បញ្ហាបរិស្ថានសំខាន់ៗសម្រាប់ដាក់បញ្ចូលទៅក្នុងរបៀបវារៈជាសកលស្តីពីបរិស្ថាន ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងអភិបាលកិច្ចនៃកម្មវិធីបរិស្ថានសហប្រជាជាតិ ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងថ្នាក់តំបន់ និងអន្តររដ្ឋាភិបាល និងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងការអនុវត្តរបៀបវារៈក្រោយឆ្នាំ២០១៥។ លទ្ធផលសំខាន់ៗពីសន្និសីទសង្គមស៊ីវិលអាស៊ីប៉ាស៊ីហ្វិចស្តីពីនិរន្តរភាពបរិស្ថានមាន៖

- បញ្ហាបរិស្ថានត្រូវបានដាក់ចូលក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ និងទិសដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។
- ទិសដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) អនុម័តវិធីយកសិទ្ធិជាមូលដ្ឋាន និងស្ថានប្រព័ន្ធជាមូលដ្ឋាន ជារបៀបវារៈអភិវឌ្ឍន៍។
- ទិសដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពថ្មី (SDGs) គប្បីបញ្ចូលគោលដៅនិងសុចនាករសំខាន់ៗ ដើម្បីធ្វើឲ្យខ្យល់ស្អាត និងលទ្ធភាពមានទឹកស្អាតប្រកបដោយសមធម៌ រួមទាំងទឹកស្អាតសម្រាប់ផឹក ដែលមានសុវត្ថិភាព ទ្រទ្រង់ទីក្រុង និងការតាំងទីលំនៅដោយនិរន្តរភាព ទ្រទ្រង់ដល់តំបន់ដែលគ្មានការបំពុល។
- ធានាដំណើរការអភិរក្សជីវចម្រុះ ទទួលបាន និងចែករំលែក ផលប្រយោជន៍ដោយសមធម៌ពីការប្រើប្រាស់ដោយនិរន្តរភាព។
- កាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- សន្សំសំចៃថាមពល និងថាមពលកកើតឡើងវិញ ដែលត្រឹមត្រូវ
- ការពារ ស្តារ អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ (គ្រប់គ្រងខ្យល់ ទឹក សមុទ្រ ដី និងព្រៃឈើ)។
- យន្តការសកលដែលពេញលេញសម្រាប់គ្រប់គ្រងសកម្មភាពរួមរបស់បណ្តាជាតិនានា
- មធ្យោបាយនៃការអនុវត្ត (ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងកសាងសមត្ថភាព) ត្រូវតែបានដោះស្រាយក្នុងគ្រប់ទិសដៅ និងគប្បីបកប្រែដល់ថ្នាក់មូលដ្ឋាន។
- បង្កើតសុចនាករ ទាំងបរិមាណ និងគុណភាព ដែលល្អប្រសើរសម្រាប់វាស់វែងផលប៉ះពាល់បរិស្ថានសង្គម។
- ទទួលស្គាល់ផលប៉ះពាល់បរិស្ថាន និងសង្គមឆ្លងដែននៃគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ
- សង្គមស៊ីវិលមានតួនាទីសំខាន់ក្នុងការបង្កើតគោលនយោបាយ ដែលជាឬសគល់ទាក់ទងនឹងសហគមន៍រងផលប៉ះពាល់។ ធាតុចូលរបស់សង្គមស៊ីវិលថ្នាក់អាស៊ីប៉ាស៊ីហ្វិក អាចត្រូវបានសម្របសម្រួលកែលំអការរៀបចំកម្រិតតំបន់ ក្នុងដំណើរការសកល តាមរយៈការបង្កើនការគាំទ្រ បង្កើតយន្តការសម្របសម្រួលក្រុមសំខាន់ៗ ធានានូវភាពស្របច្បាប់ និងអណត្តិរបស់ក្រុមសំខាន់ៗច្រើនជាងមុន នាំអាស៊ីប៉ាស៊ីហ្វិកក្នុងថ្នាក់តំបន់ ទៅក្នុងកិច្ចប្រជុំរបស់ UNEP ដោយធានាយោបល់ត្រឡប់ទៀងទាត់ និងតាមដានសមាជិកក្រុមធំ បង្កើតឱកាសភ្ជាប់ជាមួយតំណាងរដ្ឋាភិបាលនៅថ្នាក់តំបន់ ប្រើប្រាស់បច្ចេកវិទ្យាផ្សាយផ្ទាល់នៃការប្រជុំ

តាមរយៈអ៊ីនធើណែត ធានាថា មានដំណើរការពិគ្រោះយោបល់នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់ក្រោមតំបន់ខ្លាំងជាងមុន។

- សេដ្ឋកិច្ចបៃតង និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព ដោយទទួលស្គាល់ការកម្រិតស្ថានប្រព័ន្ធក្នុងការប្រើប្រាស់មានលក្ខណៈបៃតង ធានានូវធនធានប្រសិទ្ធិភាពច្រើនជាងមុន ធ្វើឲ្យឧស្សាហកម្មប្រើដំណោះស្រាយបៃតង ផ្លាស់ប្តូរប្រព័ន្ធថាមពលដែលមាននិរន្តរភាព និងបង្កើនផលិតផលថាមពលកកើតឡើងវិញ ធានាឲ្យមានព័ត៌មានត្រឡប់ទៀងទាត់ ឆាប់រហ័ស និងតាមដានសមាជិកក្រុមធំ ដើម្បីឲ្យមានតម្លាភាព គណនេយ្យភាព និងភាពស្របច្បាប់ បង្កើតឱកាសជួបផ្ទាល់ជាមួយរដ្ឋាភិបាលនៅតាមតំបន់។
- រៀបចំថវិកាបៃតង តាមរយៈ សវនកម្មថវិកា ធ្វើឲ្យឧស្សាហកម្ម និងសាធារណៈខិតខំអនុវត្តដំណោះស្រាយបៃតង ណែនាំឲ្យមានគោលនយោបាយសម្រាប់ថវិកាបៃតង ដោយយកចិត្តទុកដាក់លើការបង្កើតគោលនយោបាយលើដីទំនេរ បង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការគ្រប់គ្រងសំណល់។
- ការតៀងគរសហគមន៍ឆ្ពោះទៅរកដំណោះស្រាយបៃតង និងរៀបចំគោនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈការអប់រំ ពង្រឹងការងារលើដំណោះស្រាយ ផ្តែកលើសហគមន៍ចំពោះនិរន្តរភាពជីវភាព ទេសចរណ៍ធម្មជាតិ និងប្រពភថាមពល ការគ្រប់គ្រងសំណល់នៅថ្នាក់សហគមន៍។
- គាំទ្រលើការទទួលខុសត្រូវទូទៅប៉ុន្តែខុសគ្នា និងបង្កើតភាពយុត្តិធម៌ តាមរយៈការផ្តល់ឱកាសដល់សហគមន៍ លើកឡើងនូវតម្រូវការ គាំទ្រការកើនឡើងនូវការប្រើប្រាស់របស់ប្រជាជនក្រីក្រឆ្លើយតបនឹងតម្រូវការម្ហូបអាហារ សុខភាព និងផ្ទះសម្បែង ផ្លាស់ប្តូរឥរិយាបថ និងរបៀបរស់នៅរបស់សាធារណៈជន បញ្ចុះបញ្ចូលរដ្ឋាភិបាល និងស្ថាប័នពហុភាគីបង្កើតគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចថ្នាក់ជាតិ និង អន្តរជាតិឲ្យមានយុត្តិធម៌។

សារធាតុគីមី និងសំណល់ មានផលប៉ះពាល់លើជីវភាពរស់នៅនៃការធ្វើកសិកម្ម និងសហគមន៍ជនបទ ដោយសារកសិកម្មបែបឧស្សាហកម្ម និងឧស្សាហកម្មរ៉ែ។ គ្រោះភ័យនៃការបញ្ចេញចោលសារធាតុគីមី និង GMOs កំពុងប៉ះពាល់ដល់សន្តិសុខស្បៀង សុខភាពមនុស្ស និងស្ថានប្រព័ន្ធ។ យើងសូមអំពាវនាវឲ្យមានវិធានការដូចខាងក្រោម៖

- **ថ្នាក់ជាតិ:** ហាមមិនឲ្យបញ្ចេញសំណល់រ៉ែចូលក្នុងទន្លេ និងសមុទ្រ។ លើកទឹកចិត្តរដ្ឋាភិបាលចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធ បង្កើតគណៈកម្មការអង្កេតការបំពុលដោយ

ក្រុមហ៊ុនរ៉ែ លើកកម្ពស់ការផ្តល់វិញ្ញាបនប័ត្រដល់សហគមន៍មូលដ្ឋាន សម្រាប់ផលិតផលសរីរាង្គ បង្កើតការពិនិត្យតាមដាន និងវាយតម្លៃផលប៉ះពាល់ (សុខភាពមនុស្ស គុណភាពដីខ្យល់ និងទឹក) បង្កើតឲ្យមានវិធីសាស្ត្របែបចូលរួម សម្រាប់ស្ត្រីជនបទដើម្បីផ្លាស់ប្តូរប្រព័ន្ធកសិកម្ម ការគ្រប់គ្រងសំណល់ និងកែច្នៃសំណល់នៅមូលដ្ឋាន លើកទឹកចិត្តរដ្ឋាភិបាលអនុវត្តច្បាប់ប្រើប្រាស់សារធាតុគីមី ពង្រឹងការអនុវត្តសមត្ថភាពអ្នកប្រើប្រាស់ និងលក់ដូរសារធាតុគីមី ដាក់បញ្ចូលសេវាកម្មបរិស្ថានក្នុងប្រព័ន្ធសេដ្ឋកិច្ចសង្គម បង្កើនគណនេយ្យភាពរបស់អ្នកបំពុល គោរព និងលើកកម្ពស់ចំណេះដឹង ជំនាញនិងការអនុវត្តការចិញ្ចឹមជីវិតដោយនិរន្តរភាព។

- **ថ្នាក់អន្តរជាតិ៖** អញ្ជើញអ្នកទំនាក់ទំនងពិសេសពីវេទិកាអចិន្ត្រៃយ៍សហប្រជាជាតិស្តីពីជនជាតិដើមភាគតិចបញ្ចប់របាយការណ៍ស្តីពីអនុលោមភាព បង្កើតបរិក្ខានៅថ្នាក់អនុតំបន់និង/ឬតំបន់ សម្រាប់បញ្ចេញសំណល់ដែលមានគ្រោះភ័យ និងផលិតផលដែលមានសារធាតុពុល បង្កើតបរិក្ខានៅថ្នាក់អនុតំបន់និង/ឬតំបន់ សម្រាប់កម្មវិធីតាមដានសុខភាពមនុស្ស បង្កើតយន្តការថ្នាក់អនុតំបន់និង/ឬតំបន់ ដើម្បីវាយតម្លៃផលប៉ះពាល់បរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលអាចកើតមាន សហការបន្ថែមជាមួយនឹង FAO និង UNEP លើការផ្តល់មូលនិធិចំពោះការធ្វើកសិកម្មសរីរាង្គ។

## ៦. តួនាទីរបស់មជ្ឈមណ្ឌលធុរកិច្ច និងសិទ្ធិមនុស្ស (Business and Human Rights Resource Centre) នៅអង្គការមិនមែនរដ្ឋាភិបាល

**លោកស្រី ម៉ារតា កាស៍តេឡាន** អតីតអ្នកស្រាវជ្រាវគម្រោងរបស់មជ្ឈមណ្ឌលធុរកិច្ច និងសិទ្ធិមនុស្ស បានលើកឡើងថា មជ្ឈមណ្ឌលនេះជាអង្គការមិនមែនរដ្ឋាភិបាល ដែលបានបង្កើតឡើងក្នុងឆ្នាំ ២០០៣ ដោយលោក គ្រីស្តូហ្វ័រ អេវើរ ដែលធ្លាប់បានធ្វើការជាមួយអង្គការ Amnestry International ជានាយកខាងស្រាវជ្រាវ ដែលមានរយៈពេលជិត ១០ឆ្នាំ។ នៅពេលដែលមជ្ឈមណ្ឌលនេះបានបង្កើតឡើង មនុស្សភាគច្រើនបានពិចារណាថា ជំនួញមានការទទួលខុសត្រូវខាងសិទ្ធិមនុស្សចំពោះកម្មករ និងអ្នករងផលប៉ះពាល់ដោយដំណើរការ។ គណៈកម្មការគ្រប់គ្រងមានជំនាញផ្សេងៗគ្នា ដែលមកពីស្ថាប័នសិក្សា អ្នកជំនាញ និងអ្នកជំនួញ ដែលធានាថា មានអ្នកពាក់ព័ន្ធផ្សេងៗគ្នា។ មានបណ្តាញផ្តល់យោបល់ចំនួន ៨០ ដែលគ្រប់គ្រងដោយលោកស្រី ម៉ារី រ៉ូប៊ីនសុន និងដៃគូមកពីស្ថាប័នសិក្សាចំនួន ២០។ មជ្ឈមណ្ឌលនេះកំពុងដំណើរការក្នុងប្រទេសចំនួន ១២ ក្នុងពិភពលោក។ ការិយាល័យកណ្តាល

ស្ថិតនៅប្រទេសអង់គ្លេស។ មានអ្នកស្រាវជ្រាវ និងតំណាងមួយចំនួនក្នុងពិភពលោក។ ក្នុងប្រទេសថៃ តំណាងពិសេស និងអ្នកស្រាវជ្រាវ ទទួលខុសត្រូវគ្របដណ្តប់លើផលប៉ះពាល់នៃជំនួញលើសិទ្ធិមនុស្ស ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប្រតិកម្មដំបូងពីប្រជាជន ដែលមជ្ឈមណ្ឌលនេះមិនធ្វើការលើការទទួលខុសត្រូវសង្គម (CSR)។ ពេលវេលាភាគច្រើនគឺការងារទំនាក់ទំនងសាធារណៈ ដែលការសម្រេចចិត្តមកពីថ្នាក់កំពូលរបស់ក្រុមហ៊ុន និងសេវាកម្មសង្គម។ វិធីបែបជំនួញ និងសិទ្ធិមនុស្ស មានន័យថា ការយកចិត្តទុកដាក់លើរបៀបដែលក្រុមហ៊ុនកំពុងធ្វើឲ្យប៉ះពាល់ដល់ប្រជាជន ដោយសារប្រតិបត្តិការក្នុងសង្វាក់ផលិតកម្ម និងការងាររបស់ក្រុមហ៊ុន។ មជ្ឈមណ្ឌលមិនផលិតរបាយការណ៍ស្រាវជ្រាវច្បាប់ដើម និងធ្វើការតស៊ូមតិនោះទេ។ យើងធ្វើការងារជាបណ្ណាល័យអ៊ីនធើណែត តាមរយៈអ្នកស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មាន ក្រុមហ៊ុន និងផ្សេងៗទៀត ដើម្បីផ្តល់ព័ត៌មានស្តីពីផលប៉ះពាល់របស់ក្រុមហ៊ុនលើសិទ្ធិមនុស្ស។ គេហទំព័រកំពុងតាមដានក្រុមហ៊ុនចំនួន ៥០០០ ក្នុង ១៨០ ប្រទេស និងគ្របដណ្តប់ ១៥០ បញ្ហា ទូទាំងពិភពលោក។ ក្រៅពីនេះ ការរំលោភសិទ្ធិមនុស្ស ត្រូវបានចងក្រង មានដូចជា ការរើសអើង ផលប៉ះពាល់បរិស្ថានលើសុខភាពមនុស្ស សុខភាព និងសុវត្ថិភាព ភាពក្រីក្រ និងអភិវឌ្ឍន៍ ពលកម្មកុមារ និងលទ្ធភាពទទួលបានថ្នាំរក្សាជីវិត។ អង្គការសង្គមស៊ីវិលធ្វើការទំនាក់ទំនងជាមួយមជ្ឈមណ្ឌល បន្ទាប់មកមជ្ឈមណ្ឌលទំនាក់ទំនងក្រុមហ៊ុន និងមជ្ឈមណ្ឌលទាក់ទងអង្គការសង្គមស៊ីវិលវិញ។ ៧៥ ភាគរយ នៃក្រុមហ៊ុនឆ្លើយតបមជ្ឈមណ្ឌល។ ការឆ្លើយតបរបស់ក្រុមហ៊ុនចំពោះមជ្ឈមណ្ឌលមានឥទ្ធិពលមួយចំនួន ប៉ុន្តែមានករណីមួយចំនួន។ មានអត្រាឆ្លើយតបរបស់ក្រុមហ៊ុនក្នុងអាស៊ី (ម៉ាឡេស៊ី ៦៧% សិង្ហបុរី ៧៥% ចិន ៥០% និង ឥណ្ឌា តិចជាង ៥០%)។ នៅពេលយើងឃើញក្រុមហ៊ុនឆ្លើយតប យើងសង្កេតឃើញថា មានការកែលំអគោលនយោបាយមួយចំនួនរបស់ក្រុមហ៊ុន។

### កិច្ចពិភាក្សា

- ទាក់ទងនឹងសិទ្ធិមនុស្ស និងជំនួញ នៅមិនទាន់បានផ្សព្វផ្សាយដល់តំបន់ដាច់ស្រយាលនៅឡើយទេ ជាពិសេស ជនជាតិដើមភាគតិច សូមសំណូមពរដល់អង្គការសង្គមស៊ីវិលយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយអំពីគោលការណ៍ និងជំនួញ ដល់ជនជាតិដើមភាគតិច ជាពិសេសការរំលោភសិទ្ធិមនុស្ស។

## ៧. ខ្លឹមសារសង្ខេបនៃកិច្ចប្រជុំ និងបិទកិច្ចប្រជុំ

**លោក គាម មករាឌី** បានថ្លែងអំណរគុណចំពោះវាគ្មិន ដែលបានចែករំលែកព័ត៌មានសំខាន់ៗ ទាក់ទងនឹងមូលនិធិប្រែប្រួលអាកាសធាតុកម្ពុជា លទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីការប្រើប្រាស់ថវិកាប្រែប្រួលអាកាសធាតុ ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការគ្រប់គ្រងរបស់វេទិកានៃ

អង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ការពិគ្រោះយោបល់របស់សង្គមស៊ីវិលលើធាតុចូលសម្រាប់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨ ការចែករំលែកលទ្ធផលសំខាន់ៗពីសន្និសីទសង្គមស៊ីវិលអាស៊ីប៉ាស៊ីហ្វិកស្តីពីនិរន្តរភាពបរិស្ថាន ក្នុងរបៀបវារៈនៃការអភិវឌ្ឍក្រោយឆ្នាំ២០១៥ និងការងាររបស់មជ្ឈមណ្ឌលធុរកិច្ច និងសិទ្ធិមនុស្ស។ លោកក៏បានថ្លែងអំណរគុណចំពោះសមាជិកទាំងអស់ដែលមានវត្តមាន និងចំណាយពេលវេលាចូលរួមកិច្ចប្រជុំនេះ។

---ចប់---